**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ២៧៧៦ **អយក.** ប្រក

# ប្រកាស
# ស្តីពី
# បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងរៀបចំគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ ឱ្យមានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ របៀបរៀបរយ វិន័យ និងសីលធម៌ល្អ ក្នុងគោលដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ ។

Downloaded from http://www.khmerlaws.com

**ប្រការ ២.- វិសាលភាព**

បទបញ្ជាផ្ទៃក្នុងនេះ សម្រាប់អនុវត្តតែគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈប៉ុណ្ណោះ ។

## ជំពូកទី ២

## លក្ខខណ្ឌចូលរៀន

**ប្រការ ៣.- ការចូលរៀន**

- សិស្សទាំងអស់ដែលរៀននៅមធ្យមសិក្សាចំណេះទូទៅ ត្រូវនៅលីវ និងជាគ្រហស្ថ
- សិស្សដែលអនុញ្ញាតឱ្យចូលរៀនថ្នាក់ទី៧ នៃមធ្យមសិក្សាបឋមភូមិបាន ជាសិស្សថ្នាក់ទី៦ នៃបឋមសិក្សា ដែលមានមធ្យមភាគពិន្ទុប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ
- សិស្សដែលអនុញ្ញាតឱ្យចូលរៀនថ្នាក់ទី១០ នៃមធ្យមសិក្សាទុតិយភូមិបាន ជាសិស្សដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ សញ្ញាបត្រសមមូល ។

**ប្រការ ៤.- សំណុំលិខិតចុះឈ្មោះចូលរៀន**

- សំណុំលិខិតចូលរៀនថ្នាក់ទី៧ ជាទូទៅត្រូវមានពាក្យសុំចូលរៀន សលាកបត្រឯកត្តជន សេចក្តីចម្លងសំបុត្រកំណើត និងរូបថត
- សំណុំលិខិតចូលរៀនថ្នាក់ទី១០ ចំពោះសិស្សដែលប្តូរគ្រឹះស្ថានមធ្យមសិក្សា ពីអនុវិទ្យាល័យទៅវិទ្យាល័យ គោលដៅក្នុងរាជធានី ខេត្តសាមី ជាទូទៅត្រូវមានសៀវភៅសិក្ខាគារិក ពាក្យសុំចូលរៀន សលាកបត្រឯកត្តជន សេចក្តីចម្លងសំបុត្រកំណើត និងរូបថត ។

**ប្រការ ៥.- ការផ្ទេរការសិក្សា**

ចំពោះសិស្សមធ្យមសិក្សាបឋមភូមិ នាយកសាលាដើម ត្រូវរៀបចំសំណុំបែបបទ ដោយពិនិត្យ និងផ្ទៀងផ្ទាត់ ឱ្យបានច្បាស់លាស់ពីឈ្មោះសិស្ស ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្តាយ ដែលចុះក្នុងសៀវភៅ សិក្ខាគារិកជាមួយនឹងបណ្ណគ្រួសារ ឬ សៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើតរបស់សិស្ស ដោយគិតតាំងពីសំណេរឡើងទៅ។ ក្នុងករណីមានការខុសឆ្គង ឬ លម្អៀង ត្រូវកែតម្រូវ ជៀសវាងការសុំកែតម្រូវអាយុ ឬ ឈ្មោះ ក្រោយពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ។ បើមានកំណែតម្រូវក្នុងសៀវភៅសិក្ខាគារិក ត្រូវកែ និងចុះហត្ថលេខា និងឈ្មោះទទួលស្គាល់ដោយទឹកប៊ិចពណ៌ក្រហម ។ ការផ្ទេរការសិក្សារបស់សិស្សមធ្យមសិក្សាបឋមភូមិ ពុំចាំបាច់ឆ្លងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅទេ ។

Downloaded from http://www.khmerlaws.com

ចំពោះសិស្សមធ្យមសិក្សាទុតិយភូមិ នាយកសាលាដើម ត្រូវរៀបចំសំណុំបែបបទ ដោយពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់ពីឈ្មោះសិស្ស ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ ដែលចុះក្នុងសៀវភៅសិក្ខាគារិកជាមួយនឹងវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ដោយគិតតាំងពីសំណោរឡើងទៅ។ ក្នុងករណីមានការខុសឆ្គង ឬ លម្អៀងពីវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ គប្បីកែតម្រូវក្នុងសៀវភៅសិក្ខាគារិកដោយចុះហត្ថលេខា និងឈ្មោះទទួលស្គាល់ដោយទឹកប៊ិចពណ៌ក្រហម។ ការផ្ទេរការសិក្សា ត្រូវឆ្លងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ លើកលែងតែការផ្ទេរការសិក្សាក្នុងរាជធានី ខេត្ត ត្រូវសម្រេចដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមី។

**ប្រការ ៦.- ការអនុញ្ញាតឱ្យចូលរៀន**

ការអនុញ្ញាតឱ្យចូលរៀនក្នុងកម្រិតថ្នាក់ណាមួយ នៃគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅជាសមត្ថកិច្ចរបស់នាយក នាយិកាគ្រឹះស្ថានសិក្សា ដោយអនុវត្តសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងនីតិវិធីរដ្ឋបាល។

## ជំពូកទី ៣

## ករណីយកិច្ចរបស់សិស្ស

**ប្រការ ៧.- សម្លៀកបំពាក់ ការតុបតែងខ្លួន និងអនាម័យ**

- សិស្សទាំងអស់ត្រូវមានសម្លៀកបំពាក់ស្អាតជានិច្ច សិស្សប្រុសត្រូវស្លៀកពាក់អាវសបើកកសកក្នុងខោ វែងខៀវចាស់ រីឯសិស្សនារីត្រូវស្លៀកពាក់អាវសសកក្នុងសំពត់ ខៀវចាស់ក្រោមជង្គង់។ នៅលើផ្ទៃអាវផ្នែកខាងលើហោប៉ៅអាវ ត្រូវប៉ាក់ឈ្មោះគ្រឹះស្ថានសិក្សា ឈ្មោះថ្នាក់ និងឈ្មោះសាមីខ្លួន
- សិស្សទាំងអស់ត្រូវមានអនាម័យជានិច្ច ទាំងសម្លៀកបំពាក់ ខ្លួនប្រាណ និងចំណីអាហារ
- សិស្សទាំងអស់ត្រូវតុបតែងខ្លួនឱ្យសមរម្យ សិស្សប្រុសត្រូវកាត់សក់ខ្លី រីឯសិស្សស្រី ត្រូវសិតសក់ ដាក់បូ ឬ ចង ឬ ក្រង ឬ កាត់សក់ខ្លីត្រឹមស្មារ។

ការតុបតែងខ្លួនឱ្យឆើតឆាយ និងពាក់គ្រឿងអលង្ការផ្សេងៗ ដូចជាសិស្សប្រុសពាក់ក្រវិល សិស្សស្រីពាក់ ចង្រ្កងជើងនៅកជើង ដាំត្បូងនៅធ្មេញ លាបក្រចកដៃ លាបក្រចកជើង លាបសក់ពណ៌ផ្សេងៗ ផាត់ម្សៅ លាបក្រែម និងពាក់ស្បែកជើងមិនសមរម្យ ត្រូវហាមឃាត់ ។

Downloaded from http://www.khmerlaws.com

**ប្រការ ៨.- វិន័យ និងសីលធម៌**

**ក. សិស្សទាំងអស់ត្រូវរក្សាវិន័យ និងសីលធម៌ល្អ ដូចជា:**

- ចូលរួមគោរពទង់ជាតិ
- ឈរតម្រៀបជួរឱ្យមានរបៀបរៀបរយ និងស្ងៀមស្ងាត់ មុនពេលគោរពទង់ជាតិ និងមុនពេលចូលបន្ទប់រៀន
- រក្សាសណ្ដាប់ធ្នាប់ និងវិន័យទាំងនៅក្នុងទីធ្លាគ្រឹះស្ថានសិក្សា និងក្នុងបន្ទប់រៀននៅពេលរៀនសូត្រ ពេលចេញលេង និងចេញពីរៀន
- មានអាកប្បកិរិយាស្លូតបូត សុភាពរាបសា តែម៉ឺងម៉ាត់ ចេះស្រឡាញ់រាប់អានគ្នា ជួយយកអាសាមិត្តភ័ក្តិ មានសុជីវធម៌ គោរពមាតាបិតា គោរពចាស់ព្រឹទ្ធាចារ្យ គោរពលោកគ្រូ អ្នកគ្រូ
- ក្រោកឈរដោយស្ងៀមស្ងាត់ និងលើកដៃសំពះដោយទន់ភ្លន់ ពេលលោកគ្រូ អ្នកគ្រូ ឬ ភ្ញៀវចូលក្នុងថ្នាក់ ឬ ចេញពីថ្នាក់
- ខិតខំយកចិត្តទុកដាក់រៀនសូត្រ អនុវត្តតាមការណែនាំល្អៗរបស់លោកគ្រូ អ្នកគ្រូ
- ស្វ័យសិក្សាដោយស្ងាត់ស្ងៀមក្រោមការគ្រប់គ្រងរបស់ប្រធានថ្នាក់ នៅពេលអវត្តមាន លោកគ្រូ អ្នកគ្រូ ក្នុងម៉ោងសិក្សាមុខវិជ្ជាណាមួយ
- ស្មោះត្រង់រវាងគ្នា និងចំពោះគ្រឹះស្ថានសិក្សា ប្រសិនបើសិស្សណាម្នាក់រើសបានវត្ថុអ្វីមួយត្រូវយកទៅប្រគល់ជូនទីចាត់ការដើម្បីចាត់ចែងផ្សព្វផ្សាយ និងប្រគល់ជូនម្ចាស់ដើមវិញ
- រាយការណ៍ជាបន្ទាន់ជូនលោកគ្រូ អ្នកគ្រូ ឬ នាយក នាយិកា នូវរាល់បាតុភាពអវិជ្ជមាន និងឧបទ្ទវហេតុផ្សេងៗ ដែលកើតមានឡើងក្នុងគ្រឹះស្ថានសិក្សា។

**ខ.សិស្សទាំងអស់មិនគប្បីធ្វើអំពើ ដែលប៉ះពាល់ដល់កិត្តិយសសេចក្ដីថ្លៃថ្នូររបស់គ្រឹះស្ថានសិក្សា និងប្រទេសជាតិដូចជា :**

- ចេញ ឬ ចូលបន្ទប់រៀនដោយគ្មានការអនុញ្ញាតពីលោកគ្រូ អ្នកគ្រូក្នុងពេលកំពុងរៀន
- ប្រើប្រាស់ទូរស័ព្ទដៃ ឬ លេងហ្គេមក្នុងទូរស័ព្ទដៃក្នុងពេលកំពុងរៀន
- រំខានដល់មិត្តភក្តិ ថ្នាក់ជិតខាង និងថ្នាក់ដទៃទៀតដែលកំពុងរៀននៅពេលអវត្តមាន លោកគ្រូ អ្នកគ្រូក្នុងម៉ោងសិក្សា
- លួចចម្លង ឬ យកកិច្ចការពីអ្នកដទៃ
- យកអាវុធ គ្រឿងផ្ទុះ គ្រឿងញៀនចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា
- ពាក់មួក ជិះកង់ ម៉ូតូ ឡានក្នុងបរិវេណគ្រឹះស្ថានសិក្សា

Downloaded from http://www.khmerlaws.com

- មើលភាពយន្ត សៀវភៅរឿង ទស្សនាវដ្តីរូបភាពអាសអាភាស និងប្រព្រឹត្តអំពើអាសអាភាស អំពើដែលនាំឱ្យមានគ្រោះថ្នាក់ ឬ អំពើដែលនាំឱ្យបាត់សណ្តាប់ធ្នាប់នៅក្នុងគ្រឹះស្ថានសិក្សា
- ជក់បារី ប្រើប្រាស់គ្រឿងញៀន សេពគ្រឿងស្រវឹង និងលេងល្បែងស៊ីសងក្នុងបរិវេណគ្រឹះស្ថានសិក្សា
- និយាយមិនសមរម្យ គំរាមកំហែង នាយក នាយិកា និងបុគ្គលិកអប់រំផ្សេងទៀត ឬ បង្កើតក្រុមបង្កអសុវត្ថិភាពក្នុងគ្រឹះស្ថានសិក្សា
- គូសវាស សរសេរ ឬ កោសលើរបង ជញ្ជាំងសាលារៀន និងសម្ភារីម ឬ បំផ្លិចបំផ្លាញឱ្យបែកបាក់សម្ភារីម និងអគារសិក្សា។ សិស្សដែលធ្វើឱ្យខូចខាតទ្រព្យសម្បត្តិគ្រឹះស្ថានសិក្សា ដោយចេតនា ត្រូវឱ្យមាតាបិតា ឬ អ្នកអាណាព្យាបាល ឬ អ្នកគ្រប់គ្រងថែរក្សា ជួសជុល ឬ សងជំនួសវិញ
- ធ្វើអ្វីដែលប្រឆាំងច្បាប់រដ្ឋ និងទំនៀមទម្លាប់ប្រពៃណីជាតិ ។

**ប្រការ ៩.- ការគោរពទង់ជាតិ**

គ្រប់គ្រឹះស្ថានសិក្សាសាធារណៈត្រូវប្រារព្ធពិធីគោរពទង់ជាតិ ដូចខាងក្រោម ÷

- រៀងរាល់ព្រឹកថ្ងៃច័ន្ទមុនពេលចូលរៀន ត្រូវឱ្យសិស្សច្រៀងវគ្គទីមួយ នៃបទនគររាជ និងបទសារ៉ាវ៉ាន់ខ្មែរ
- រៀងរាល់ថ្ងៃសៅរ៍មុនពេលចេញទៅផ្ទះ ត្រូវឱ្យសិស្សច្រៀងទាំងបីវគ្គ នៃបទនគររាជ និងបទសារ៉ាវ៉ាន់ខ្មែរ ។

**ប្រការ ១០.- ការចូលរួមសកម្មភាពរបស់គ្រឹះស្ថានសិក្សា**

សិស្សទាំងអស់ត្រូវ ÷

- មករៀនទាន់ពេលវេលា ពិសេស សិស្សដែលដល់វេនសំអាតតាមកាលវិភាគកំណត់ ត្រូវមកដល់គ្រឹះស្ថានសិក្សា៣០នាទី មុនពេលចូលរៀន ដើម្បីសំអាតទីធ្លា បង្គន់អនាម័យ និងបន្ទប់រៀន
- ចូលរួមគ្រប់សកម្មភាពរបស់គ្រឹះស្ថានសិក្សា ដែលក្រៅពីការធ្វើអនាម័យគ្រឹះស្ថានសិក្សា និងបន្ទប់រៀន មានដូចជា ការថែរក្សាសួនច្បារ សួនបន្លែ ដាំ និងថែទាំដើមឈើ ចិញ្ចឹមសត្វ ធ្វើពលកម្ម និងយាមរក្សាសន្តិសុខ និងសុវត្ថិភាពគ្រឹះស្ថានសិក្សា
- ចូលរួមគ្រប់សកម្មភាពសង្គម ក្រោមការដឹកនាំរបស់នាយក នាយិកា គ្រូទទួលបន្ទុកថ្នាក់ និងក្រុមប្រឹក្សាយុវជន ដូចជាការចូលរួមពិធីបុណ្យក្នុងវត្តអារាម ដង្ហែក្បួននានា ការច្រូតកាត់ ព្រមទាំងចូលរួមទទួលថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលជាដើម

ដើម្បីឱ្យសកម្មភាពនេះមានដំណើរការល្អ គ្រប់គ្រឹះស្ថានសិក្សា ត្រូវរៀបចំក្រុមប្រឹក្សាយុវជនដោយប្រគល់តួនាទី និងភារកិច្ចឱ្យបានច្បាស់លាស់ ។

Downloaded from http://www.khmerlaws.com

**ប្រការ ១១.- ទណ្ឌកម្ម**

- រាល់ទណ្ឌកម្មលើរាងកាយ និងស្មារតីសិស្ស ត្រូវហាមឃាត់ដាច់ខាតនៅក្នុងគ្រឹះស្ថានសិក្សា
- ចំពោះសិស្សដែលប្រព្រឹត្តខុស ត្រូវដាក់ឱ្យក្រុមប្រឹក្សាវិន័យពិនិត្យ និងសម្រេចទៅតាមកម្រិតនៃកំហុស និងក្រោមរូបភាព ដូចជា ណែនាំ ស្តីបន្ទោសដោយចុះក្នុងសៀវភៅសិក្ខាគារិក ព្រមានជាលាយលក្ខណ៍អក្សរ ផ្អាកការសិក្សាបណ្តោះអាសន្ន លុបឈ្មោះចេញពីបញ្ជីសិក្សា បញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ។ ល ។
- ការគាបសង្កត់សិស្សគ្រប់រូបភាពដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវហាមឃាត់ដាច់ខាតនៅគ្រប់គ្រឹះស្ថានសិក្សា និងបន្ទប់រៀន។

## ជំពូកទី ៤
## លក្ខខណ្ឌនៃការសិក្សា

**ប្រការ ១២.- ការសុំច្បាប់ឈប់សម្រាក**

- សិស្សទាំងអស់ត្រូវសុំច្បាប់ឈប់សម្រាកនៅពេលមានធុរៈ ឬ មានជម្ងឺផ្សេងៗ។ រាល់ការឈប់ដែលគ្មានការអនុញ្ញាត ត្រូវកំណត់ថាជាការឈប់ "អត់ច្បាប់"
- ការឈប់ដោយឈឺ ដោយមានច្បាប់ ឬ ដោយអត់ច្បាប់ក្នុង រយៈពេលមួយម៉ោងសិក្សា ឬ មួយព្រឹក ឬ មួយរសៀល ត្រូវគិតថាឈប់ "មួយដង"
- សិស្សដែលមករៀនមិនទាន់ពេល ឬ មករៀនយឺត ត្រូវមកសុំការអនុញ្ញាតពីទីចាត់ការ ឬ សុំការអនុញ្ញាតពីគ្រូបង្រៀនផ្ទាល់
- ការសុំច្បាប់ឈប់សម្រាកត្រូវឱ្យមាតាបិតា ឬ អ្នកអាណាព្យាបាល ឬ អ្នកគ្រប់គ្រងថែរក្សាសរសេរលិខិត ឬ មកផ្ទាល់ស្នើសុំច្បាប់សម្រាក មកលោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់ ឬ ទីចាត់ការ ដោយបញ្ជាក់ពីមូលហេតុពិតប្រាកដ
- លោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់ អាចអនុញ្ញាតឱ្យសិស្សឈប់សម្រាកមួយពេល បើលើសពីនេះ ជាភារកិច្ចរបស់នាយក នាយិកាគ្រឹះស្ថានសិក្សា
- សិស្សដែលចូលរៀនវិញក្រោយពីការឈប់សម្រាក ត្រូវយកលិខិតអនុញ្ញាតច្បាប់ប្រគល់ជូនលោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់ ឬ គ្រូមុខវិជ្ជាឯកទេស ។

**ប្រការ ១៣.- អវត្តមាន និងបទវិន័យ**

សិស្សទាំងឡាយត្រូវខិតខំយកចិត្តទុកដាក់រៀនសូត្រ និងធ្វើគ្រប់កិច្ចការដែលគ្រូដាក់ឱ្យធ្វើ ព្រមទាំងមករៀនឱ្យបានទៀងទាត់ ។

Downloaded from http://www.khmerlaws.com

ក.ករណីទី១: ចំពោះសិស្សអវត្តមាន ដូចមានក្នុងប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣ខាងក្រោម ត្រូវរៀនត្រួតថ្នាក់ ក្នុងករណីធ្លាក់មធ្យមភាគពិន្ទុប្រចាំឆ្នាំ។ បើជាប់មធ្យមភាគពិន្ទុប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតឱ្យប្រឡងឡើងថ្នាក់ ÷

- ប្រភេទទី១ : ឈប់អត់ច្បាប់លើសពី ៣០ ដងឡើងទៅ
- ប្រភេទទី ២ : ឈប់អត់ច្បាប់ និងមានច្បាប់លើសពី ៤០ ដងឡើងទៅ
- ប្រភេទទី ៣ : ឈប់មានច្បាប់លើសពី ៥៥ ដងឡើងទៅ។

ខ.ករណីទី២: ចំពោះសិស្សដែលឈប់អត់ច្បាប់លើសពី ៥៥ដង ត្រូវលុបឈ្មោះចេញពីបញ្ជីរបស់គ្រឹះស្ថានសិក្សា។

**ប្រការ ១៥.- របបពិន្ទុ ការឡើងថ្នាក់ និងត្រួតថ្នាក់**

- សិស្សឈប់អត់ច្បាប់ក្នុងពេលប្រឡងឆមាសមុខវិជ្ជាណាមួយ ត្រូវបានពិន្ទុសូន្យចំពោះមុខវិជ្ជានោះ
- សិស្សឈប់អត់ច្បាប់ ឬ មានច្បាប់ក្នុងពេលប្រឡងឆមាសចាប់ពី ០៣ មុខវិជ្ជាឡើងទៅ មិនត្រូវធ្វើចំណាត់ថ្នាក់ និងត្រូវរៀនត្រួតថ្នាក់ តែបើករណីមានជំងឺ ឬ មានគ្រោះថ្នាក់ជាក់ស្តែងព្រមទាំងមានវិញ្ញាបនបត្រពេទ្យមកបញ្ជាក់ត្រឹមត្រូវ អាចទទួលការអនុគ្រោះធ្វើចំណាត់ថ្នាក់ ឬ ឱ្យប្រឡងឡើងថ្នាក់
- ការដាក់ពិន្ទុលើគ្រប់មុខវិជ្ជាត្រូវកំណត់ពី ០ (សូន្យ) ដល់ ៥០ (ហាសិប)
- សិស្សនឹងអាចឡើងថ្នាក់បាន លុះត្រាតែមានមធ្យមភាគពិន្ទុប្រចាំឆ្នាំ ចាប់ពី ២៥.០០ លើ ៥០.០០ មានសីលធម៌រស់នៅចាប់ពីមធ្យមឡើងទៅ និងមិនស្ថិតក្នុងប្រភេទទាំងបី នៃអវត្តមានចែងក្នុងប្រការ១៤ ។ សិស្សដែលមានមធ្យមភាគពិន្ទុប្រចាំឆ្នាំក្រោម ២៥.០០ លើ ៥០.០០ ត្រូវសម្រេចឱ្យត្រួតថ្នាក់ ឬ ឱ្យប្រឡងឡើងថ្នាក់ដោយក្រុមប្រឹក្សាអប់រំ។
- ចំពោះថ្នាក់ប្រឡង សិស្សដែលគ្មានចំណាត់ថ្នាក់ ឬ មានអវត្តមានស្ថិតក្នុងប្រភេទទាំងបី នៃអវត្តមានក្នុងប្រការ ១៤ មិនអនុញ្ញាតជាបេក្ខភាពប្រឡងសញ្ញាបត្រឡើយ។

## ជំពូកទី ៥

## ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សា មាតាបិតាសិស្ស និងសហគមន៍

**ប្រការ ១៥.-ទំនាក់ទំនងរវាងសហគមន៍ និងគ្រឹះស្ថានសិក្សា**

មាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សាសិស្ស ត្រូវសហការជាមួយគ្រឹះស្ថានសិក្សា តាមដានគ្រប់សកម្មភាពរបស់សិស្ស រួមទាំងការសិក្សា ការលើកកម្ពស់ការសិក្សា ដោយទំនាក់ទំនងនាយក នាយិកា លោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់ ឬ គ្រូទទួលបន្ទុកមុខវិជ្ជាឯកទេស គ្រឹះស្ថានសិក្សាជាពិសេសត្រូវទារសៀវភៅតាមដានការសិក្សាពីសិស្សរៀងរាល់ខែ។

Downloaded from http://www.khmerlaws.com

**ប្រការ ១៦.- ទំនាក់ទំនងរវាងគ្រឹះស្ថានសិក្សា និងសហគមន៍**

គ្រឹះស្ថានមធ្យមសិក្សាត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយមាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សាសិស្ស និងសហគមន៍ ដើម្បីផ្ដល់ និងទទួលព័ត៌មាននានាពាក់ព័ន្ធនឹងបាតុភាពអវិជ្ជមានផ្សេងៗ ដែលប្រព្រឹត្តដោយសិស្ស និងសកម្មភាពដទៃទៀត ដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា។

ការផ្ដល់ព័ត៌មានសិស្សអវត្តមានអត់ច្បាប់ត្រូវអនុវត្តដូចខាងក្រោម ÷

- សិស្សឈប់អត់ច្បាប់ចំនួន ១០ដង ត្រូវព្រមានដល់សាមីខ្លួន និងជូនព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សា ទទួលដឹង និងចុះកិច្ចសន្យាជាលើកទីមួយ
- សិស្សឈប់អត់ច្បាប់ចំនួន ២០ដង ត្រូវព្រមានដល់សាមីខ្លួន និងជូនព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សា ទទួលដឹង និងចុះកិច្ចសន្យាជាលើកចុងក្រោយ
- រាល់ការផ្ដល់ព័ត៌មានទៅមាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សាសិស្ស ត្រូវធ្វើលិខិតនោះ តាមប្រៃសណីយ៍ ឬ តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រការ ១៧.- គ្រោះថ្នាក់ សុខភាព និងការការពារសុវត្ថិភាព**

- គ្រប់គ្រឹះស្ថានសិក្សា ត្រូវរៀបចំឱ្យមានហិបគិលានសង្គ្រោះបឋមសម្រាប់ជួយសិស្ស ដែលមានគ្រោះថ្នាក់ស្រាលៗដូចជា ករណីសិស្សខ្យល់គ ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរត្រូវនាំទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យដែលនៅក្បែរនោះ ហើយផ្ដល់ព័ត៌មានដល់គ្រួសារសិស្សជាបន្ទាន់
- សិស្សដែលមានជំងឺ ត្រូវអនុញ្ញាតច្បាប់ឱ្យទៅពិនិត្យរោគនៅមន្ទីរពេទ្យ ដោយយកសៀវភៅពិនិត្យសុខភាពទៅជាមួយ និងទទួលឱ្យចូលរៀនវិញនៅពេលជាសះស្បើយ
- គ្រប់គ្រឹះស្ថានសិក្សា ត្រូវរៀបចំសម្ភាររូបវន្តនានាឱ្យបានត្រឹមត្រូវ និងដាក់ស្លាកសញ្ញាសំគាល់គ្រោះថ្នាក់ផ្សេងៗ នៅកន្លែងដែលអាចកើតមាន ដូចជា អណ្ដូងទឹក ស្រះទឹក បន្ទប់អគ្គិសនី អគារទ្រុឌទ្រោម កន្លែងមានមីន ឬ គ្រាប់មិនទាន់ផ្ទុះ។ល។
- ចំពោះគ្រឹះស្ថានសិក្សាដែលមានខ្លោងទ្វារចេញចំមុខផ្លូវ និងមានចរាចរណ៍អ៊ូអរ ត្រូវរៀបចំរបាំងឃាំង ផ្លូវផ្អាកចរាចរណ៍មួយរយៈខ្លី ដើម្បីឱ្យសិស្សចេញពីគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាព។

**ប្រការ ១៨.- ប្រតិទិនឆ្នាំសិក្សា និងម៉ោងសិក្សា**

គ្រប់គ្រឹះស្ថានមធ្យមសិក្សា ត្រូវអនុវត្តប្រតិទិនឆ្នាំសិក្សា និងម៉ោងសិក្សាតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងករណីខ្វះបន្ទប់រៀន ត្រូវដោះស្រាយឱ្យរៀនពីរ ឬ បីវេន ហើយម៉ោងសិក្សាត្រូវកំណត់តាមការច្នៃប្រឌិត និងតាមស្ថានភាពជាក់ស្ដែងរបស់គ្រឹះស្ថានមធ្យមសិក្សា។

Downloaded from http://www.khmerlaws.com

ក្នុងករណីប្រធានសក្តិ គ្រឹះស្ថានសិក្សាត្រូវរាយការណ៍មកក្រសួងតាមឋានានុក្រមអំពីការផ្អាកដំណើរការសិក្សាបណ្តោះអាសន្ន និងត្រូវបំពេញការងារទាំងអស់ឡើងវិញ ជំនួសរយៈពេលនៃការខកខាននោះ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ១៩.- ការផ្សព្វផ្សាយ**

បទបញ្ជាផ្ទៃក្នុងនេះត្រូវអានពន្យល់សិស្ស និងបិទនៅក្នុងបន្ទប់រៀន ទីចាត់ការ ហើយត្រូវផ្សព្វផ្សាយដល់សហគមន៍ មាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សាសិស្សឱ្យបានយល់អំពីគោលបំណង ខ្លឹមសារ និងអត្ថន័យនៃបទបញ្ជានេះ។

**ប្រការ ២០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២១.- ការអនុវត្ត**

អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានកីឡា អគ្គនាយកដ្ឋានយុវជន អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ លោកនាយក លោកស្រី នាយិកាគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ បុគ្គលិកអប់រំ សិស្ស និងអង្គភាពពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ តុលា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សេធី**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- ដូចប្រការ ២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ : នាទីកិច្ច

Downloaded from http://